**នៅចំពោះមុខ អង្គជំនុំជម្រះសាលាដំបូង**

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ

ភាគីដាក់ឯកសារ: សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី

ដាក់ជូន: អង្គជំនុំជម្រះសាលាដំបូង

ភាសាដើម: អង់គ្លេស

កាលបរិច្ឆេទឯកសារ: ថ្ងៃទី១៤ ខែតុលា ឆ្នាំ២០១២

**ឯកសារបកប្រែ**
**TRANSLATION/TRADUCTION**
ថ្ងៃ ខែ ឆ្នាំ (Date): 15-Mar-2012, 15:23
CMS/CFO: Sann Rada

**<u>ចំណាត់ថ្នាក់ឯកសារ</u>**

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារដោយ កសចស ឬ អង្គជំនុំជម្រះ **សម្ងាត់/Confidential**

ឋានៈនៃចំណាត់ថ្នាក់ឯកសារ

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់ណ្តោះអាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

---

**សេចក្តីសង្ខេបរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីលើសេចក្តីជូនដំណឹង**
**របស់សហព្រះរាជអាជ្ញាដល់អង្គជំនុំជម្រះសាលាដំបូង និងភាគីផ្សេងៗ**
**ទាក់ទងនឹងសក្ខីកម្មរបស់សាក្សី TCE-38**

---

**<u>ដាក់ដោយ៖</u>**

**<u>សហមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណី៖</u>**

ពេជ អង្គ

Ms. Elisabeth SIMONNEAU FORT

**<u>សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖</u>**

ជេត វណ្ណលី

ហុង គឹមសួន

គឹម ម៉េងឃី

ឡោ ជុនធី

ម៉ុច សុវណ្ណារី

**<u>នៅចំពោះមុខ៖</u>**

**<u>អង្គជំនុំជម្រះសាលាដំបូង៖</u>**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម Silvia CARTWRIGHT

ចៅក្រម យ៉ា សុខន

ចៅក្រម Jean-Marc LAVERGNE

ចៅក្រម យូរ ឧត្តារា

**<u>ផ្ញើជូន៖</u>**

**<u>ការិយាល័យសហព្រះរាជអាជ្ញា៖</u>**

ស៊ិន សុវ៉ន

គង់ ពិសី

យ៉ុង ផានិត

សំ សុគង់

វ៉ែន ពៅ

ទី ស្រីនណា

Silke STUDZINSKY
Emmanuel ALTIT
Pascal AUBOIN
Olivier BAHOUGNE
Patrick BAUDOIN
Evelyne BOILEAU-BRANDOMIR
Philippe CANONNE
Annie DELAHAIE
Laure DESFORGES
Ferdinand DJAMMEN NZEPA
Nicole DUMAS
Isabelle DURAND
Françoise GAUTRY
Marie GUIRAUD
Emmanuel JACOMY
Martine JACQUIN
Daniel LOSQ
Christine MARTINEAU
Mahdev MOHAN
Barnabé NEKUIE
Lyma NGUYEN
Elisabeth RABESANDRATANA
Julien RIVET
Fabienne TRUSSES NAPROUS
Nushin SARKARATI
Philippine SUTZ

ជា លាង

Andrew T. CAYLEY

យ៉េត ចរិយា

William SMITH

**ជនជាប់ចោទ៖**

ខៀវ សំផន

អៀង សារី

អៀង ធីរិទ្ធ

នួន ជា

**សហមេធាវីការពារក្តី៖**

សុន អរុណ

Michiel PESTMAN
Victor KOPPE

អាង ឧត្តម

Michael G. KARNAVAS

ផាត់ ពៅស៊ាង

Diana ELLIS

គង់ សំអុន

Anta GUISSÉ
Arthur VERCKEN
Jacques VERGES

## I. សាវតារ

១. សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី សូមយោងទៅអនុស្សរណៈរបស់ អង្គជំនុំជម្រះសាលាដំបូង៖ ការស្តាប់សក្ខីកម្មរបស់អ្នកជំនាញដែលមានរហស្សនាម TCE-38 និង TCE-44 ឯកសារលេខ **E166** ចុះថ្ងៃទី ០៦ ខែ កុម្ភៈ ឆ្នាំ ២០១២ សេចក្តីជូនដំណឹងរបស់សហព្រះរាជអាជ្ញាដល់អង្គជំនុំជម្រះសាលាដំបូង និងភាគី ទាក់ទងនឹងសក្ខីកម្មរបស់សាក្សី TCE-38 និង TCE-44 ឯកសារលេខ **E166/1** ចុះថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ ២០១២ និង អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូង ឯកសារលេខ **E172/5** ចុះថ្ងៃទី ២ ខែ មីនា ឆ្នាំ ២០១២ ស្តីពីសវនាការលើឯកសារ ("សវនាការ") ដែលចាប់ផ្តើមនៅថ្ងៃទី ១២ ខែ មីនា ឆ្នាំ ២០១២ ។

២. ឆ្លៀតឱកាសនេះ យើងខ្ញុំសូមបញ្ជាក់ឡើងវិញនូវជំហររបស់យើងខ្ញុំទាក់ទងនឹងសក្ខីកម្មរបស់សាក្សី TCE-38 ស្របតាមអនុសាសន៍របស់សហព្រះរាជអាជ្ញាក្នុងឯកសារលេខ E166/1 ដែលស្នើឱ្យផ្តល់ជូនសហព្រះរាជអាជ្ញា ឬអង្គជំនុំជម្រះសាលាដំបូងនូវប្រធានបទ និងឯកសារដែលភាគីមានបំណងលើកមកពិភាក្សា ដើម្បីបញ្ជូនទៅឱ្យសាក្សី TCE-38។

## II. សំណើ

### ទាក់ទងនឹងប្រធានបទដែលត្រូវសួរសាក្សី TCE-38

៣. យើងខ្ញុំយល់ស្រប និងគាំទ្របញ្ជីនៃប្រធានបទដែលបានកំណត់ដោយសហព្រះរាជអាជ្ញានៅក្នុងឯកសារលេខ E166/1 (ឧបសម្ព័ន្ធ) ដែលជាការឆ្លើយតបនឹងសំណើរបស់សាក្សី TCE-38 ដែលថា គាត់អាចមានភាពងាយស្រួល បើសិនជាគាត់ទទួលបានការជូនដំណឹងជាមុនអំពីប្រធានបទដែលគាត់ត្រូវផ្តល់សក្ខីកម្មនោះ។ ក្រៅពីប្រធានបទទាំងនេះ យើងស្នើឱ្យជូនដំណឹងដល់សាក្សី TCE-38 ថា គាត់នឹងត្រូវផ្តល់សក្ខីកម្មអំពីមនុស្សដែលទាក់ទងនឹង "ក្រុមជាក់លាក់នានា" នៅក្នុងកថាខណ្ឌ ៤ ច (iv) ឯកសារលេខ E166/1(ឧបសម្ព័ន្ធ) និងការប្រព្រឹត្តទៅលើពួកគេ ដោយយោងទាំងស្រុងលើការជម្លៀសប្រជាជន (ក្នុងដំណាក់ទី១ និងដំណាក់កាលទី២) នៅក្នុងកថាខណ្ឌ៦ ក្នុងឯកសារដដែលនោះ ដែលស៊ីសង្វាក់គ្នាជាមួយនឹងផ្នែកនានានៅក្នុងដីកាដំណោះស្រាយ **D427** ដែលជាប់ទាក់ទងនឹងសវនាការដំណាក់ទី១ ក្នុងសំណុំរឿង ០០២

(**E124/7/.2**)។

**ទាក់ទងនឹងឯកសារបន្ថែមដែលត្រូវផ្តល់ជូន សាក្សី** TCE-38

៤. ក្រៅពីសៀវភៅនានាដែលបានបញ្ជាក់ក្នុងកថាខណ្ឌ ១ នៃឯកសារលេខ E166/1 (ឧបសម្ព័ន្ធ) យើងខ្ញុំស្នើឲ្យអង្គជំនុំជម្រះសាលាដំបូង បញ្ជូនឯកសារខាងក្រោមជូនសាក្សី TCE-38 ដើម្បីឲ្យគាត់អាចពិនិត្យមើលឯកសារទាំងនេះភ្លាមៗ ឬអនុញ្ញាតឲ្យសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី បញ្ជូនឯកសារទាំងនេះដល់គាត់។

ក. ឯកសារលេខ **D250/3.22** មានចំណងជើងថា "The Survival of Cambodia's Ethnic Minorities" បោះពុម្ពផ្សាយដោយ Cultural Survival ថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ១៩៩០

ខ. ឯកសារលេខ **D366/7.1.76** មានចំណងជើងថា "The Samlaut Rebellion and its aftermath 1967-1970, The Origins of Cambodia's Liberation Movement, Part 1" បោះពុម្ពផ្សាយដោយមជ្ឈមណ្ឌលសិក្សាអំពីតំបន់អាស៊ីអាគ្នេយ៍ នៃសាកលវិទ្យាល័យ Monash ។

៥. នេះមិនមែនជាសំណើថ្មីទេ។ ឯកសារទាំងពីរនេះ ស្ថិតក្នុងចំណោមឯកសារចំនួន១០ ដែលមាននៅក្នុងឧបសម្ព័ន្ធ ៧ (a) (i) នៃឯកសារ E109/2.1 ដែលសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី បានយោងនៅក្នុងលិខិតរបស់ខ្លួនផ្ញើជូនអង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី ០៨ ខែ មីនា ឆ្នាំ ២០១២។ យើងសូមកត់សម្គាល់ថា ឯកសារ D250/3.22 មិនត្រូវ បានភាគីបានជំទាស់ឡើយ។

៦. ផ្ទុយនឹងការជំទាស់នានា ដែលបានលើកឡើងដោយក្រុមមេធាវីការពារក្តីក្នុងពេលសវនាការលើឯកសារនៅថ្ងៃទី ១២ ខែមីនា ឆ្នាំ២០១២[1] វាច្បាស់ណាស់ដែលថា ការបោះពុម្ពផ្សាយការងារសិក្សាស្រាវជ្រាវនានាគឺអាចទទួលយកបាន ជាពិសេសនៅពេលដែលអ្នកនិពន្ធ ដូចជាសាក្សី TCE-38 នឹងត្រូវអញ្ជើញមកផ្តល់សក្ខីកម្មក្នុងនាមជាអ្នកជំនាញ និងអាចសួរដេញដោលដោយខាងក្រុមមេធាវីការពារក្តីដោយសារក្រុមមេធាវីការពារក្តីមានបំណងនឹង"ធ្វើការសួរដេញដោល"ពាក់ព័ន្ធនឹងឯកសារខាងលើ។ ការតាំងសំនួរនានាទាក់ទងនឹងឯកសារទាំងនេះ

[1] សូមមើលប្រតិចារឹក ថ្ងៃទី ១២ ខែ មីនា ឆ្នាំ ២០១២ សវនាការ ថ្ងៃទី៣៤ ទំព័រ ៦២ ។

អាច និងគួរតែលើកឡើងក្នុងអំឡុងពេលធ្វើសក្ខីកម្មរបស់អ្នកជំនាញរូបនេះ អាច ឬគប្បីត្រូវបានសាកសួរក្នុងពេលអ្នកជំនាញផ្តល់សក្ខីកម្ម ប៉ុន្តែ មិនអាចសាកសួរបានមុនពេលក្នុងសវនាការនេះឡើយ។

៧. ដោយសារតែ សាក្សី TCE-38 អង្គជំនុំជម្រះធ្លាប់បានកំណត់កាលវិភាគស្តាប់សក្ខីកម្មក្នុងរយៈពេលបីសប្តាហ៍នាពេលខាងមុខ ក្រុមមេធាវីការពារក្តីអាចតាំងសំណួរទៅអ្នកជំនាញ នេះ និង ឯកសារនានាដទៃទៀត ។ យោងលើឯកសារ E166 និងឯកសារ E166/1 ភាពមិនច្បាស់ថា តើសាក្សី TCE-38 នឹងត្រូវផ្តល់សក្ខីកម្មឬយ៉ាងណា គប្បីត្រូវ ដោះស្រាយ ផ្អែកលើកាលវិភាគសវនាការពេលបច្ចុប្បន្ន និងមិនផ្អែកលើការជំទាស់ដោយផ្ទាល់របស់ក្រុមមេធាវីការពារក្តីចំពោះអង្គហេតុនៃសក្ខីកម្មរបស់សាក្សី TCE-38 ឡើយ។ យើងអាចនិយាយម្យ៉ាងទៀតបានថា ក្រុមមេធាវីការពារក្តី មិនអាចផ្អែកដោយផ្ទាល់ ឬដោយប្រយោល លើការជំទាស់ដោយផ្ទាល់របស់ខ្លួនចំពោះការផ្តល់សក្ខីកម្មរបស់សាក្សី TCE-38 ដើម្បីលើកឡើងថា យើងមិនគួរបដិសេធសិទ្ធិពិនិត្យមើលខ្លឹមសារនៃឯកសារដែលនិពន្ធដោយសាក្សី TCE-38 តាមរយៈការសាកសួរសាក្សីរបស់ភាគីបដិបក្ខឡើយ។

៨. ជាចុងក្រោយ យើងយល់ថាវាជាការចម្លែក និងមិនស៊ីសង្វាក់គ្នាទាល់តែសោះដែលក្រុមមេធាវីការពារក្តី ស្នើឲ្យអង្គជំនុំជម្រះសាលាដំបូងទទួលយកឯកសារបន្ថែមពីសាក្សី TCE-38 តែខ្លួនជំទាស់នឹងការទទួលយកឯកសារបោះពុម្ពផ្សាយមួយ ដែលនិពន្ធដោយសាក្សីជំនាញរូបនេះ។ ការជំទាស់បែបនេះ ប៉ះពាល់ដល់ទឡ្ហីករណ៍ដ៏គួរឲ្យល្អដែលខ្លួនបានលើកឡើងថា ដោយហេតុថាសាក្សី TCE-38 ត្រូវបានកោះអញ្ជើញជាសាក្សីជំនាញ ភាគីមានសិទ្ធិពិនិត្យ ឯកសារណាមួយ ឬឯកសារទាំងអស់ របស់សាក្សីជំនាញរូបនោះ ដែលអាចទាក់ទងនឹង ប្រធានបទដែលគាត់អាចផ្តល់ភស្តុតាង។

## ទាក់ទងនឹងការសាកសួរសាក្សី TCE-38 តាមប្រព័ន្ធសោតទស្សន៍

៩. ចំពោះលក្ខណៈពិសេស និងសារៈសំខាន់ក្នុងការសាកសួរសាក្សីជំនាញ TCE-38 យើងយល់ឃើញថា សាក្សីជំនាញ TCE-38 រូបនេះ ជាអ្នកនិពន្ធសំខាន់មួយរូបជាសាក្សីក្នុងសវនាការដំណាក់កាលទីមួយក្នុងសំណុំរឿង០០២ ជាពិសេសគាត់មានចំណេះដឹងដោយផ្ទាល់ ឬបានធ្វើការសិក្សាស្រាវជ្រាវយ៉ាងទូលំទូលាយអំពីប្រធានបទ និងបញ្ហានានាដែលទាក់ទងនឹងឯកសារ

E166/1 ឧបសម្ព័ន្ធ ក និងកថាខណ្ឌ ៣ ដែលពាក់ព័ន្ធទៅនឹងអង្គហេតុនានា*ក្នុងនោះ* ពាកព័ន្ធនឹងវិធានការនានាប្រឆាំងនឹងក្រុមជាក់លាក់ និងមនុស្សដែលជាប់ទាក់ទងនឹងក្រុមទាំង នោះ ដែលត្រូវបានលើកឡើងក្នុងដីកាដំណោះស្រាយ ឯកសារ D427។ ដោយសារតែសាក្សី TCE-38 មិនអាចធ្វើដំណើរមកប្រទេសកម្ពុជាដើម្បីផ្តល់សក្ខីកម្មក្នុងឆ្នាំ ២០១២ អង្គជំនុំជម្រះសាលាដំបូងគប្បីខិតខំប្រឹងប្រែងដើម្បីរៀបចំឲ្យគាត់ផ្តល់សក្ខីកម្មផ្ទាល់មាត់តាមរយៈប្រព័ន្ធសោតទស្សន៍ បើមិនដូច្នេះទេ អង្គជំនុំជម្រះសាលាដំបូងនឹងបាត់បង់ឱកាសស្តាប់សក្ខីកម្មរបស់អ្នកជំនាញដ៏សំខាន់រូបនេះ និងបាត់បង់ឱកាសពិនិត្យមើលភស្តុតាងសំខាន់ៗ ដែលអាចជួយដល់អង្គជំនុំជម្រះសាលាដំបូងក្នុងធ្វើសេចក្តីសម្រេចរបស់ខ្លួន និងមានសារៈសំខាន់បំផុតសម្រាប់កំណត់ត្រាតុលាការ និងកំណត់ត្រាប្រវត្តិសាស្ត្ររបស់ អ.វ.ត.ក។

អាស្រ័យហេតុនេះ សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី សូមស្នើដោយក្តីគោរពឲ្យអង្គជំនុំជម្រះសាលាដំបូងមេត្តា៖

១. សាកសួរសាក្សី TCE-38 តាមប្រព័ន្ធសោតទស្សន៍ប្រសិនបើចាំបាច់

២.ជូនដំណឹងសាក្សី TCE-38 ថា គាត់នឹងត្រូវផ្តល់សក្ខីកម្មអំពីមនុស្សដែលជាប់ទាក់ទងនឹង “ក្រុមជាក់លាក់នានា” ក្នុងកថាខណ្ឌ ៤ ច (iv) ឯកសារលេខ E166/1 (ឧបសម្ព័ន្ធ)

៣. បញ្ជូនឯកសារ D250/3.22 និង D366/7.1 ជូនសាក្សី TCE-38 ។

សូមលោកលោកស្រីចៅក្រមទទួលយកសំណើនេះដោយសេចក្តីគោរព។

| **កាលបរិច្ឆេទ** | **ឈ្មោះ** | **ទីកន្លែង** | **ហត្ថលេខា** |
|---|---|---|---|
| ថ្ងៃទី ១៤ ខែ មីនា ឆ្នាំ ២០១២ | អង្គ ពេជ<br>សហមេធាវីនាំមុខ | ភ្នំពេញ | |
| | Elisabeth SIMONNEAU FORT<br>សហមេធាវីនាំមុខ | ភ្នំពេញ | |